ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

លេខ:............................

# សេចក្តីជូនដំណឹង

**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ** បានពិនិត្យឃើញថា មានប្រជាពលរដ្ឋមួយចំនួន ជាពិសេសសិស្ស និស្សិត អាជីវករ កម្មករ និងកម្មការិនី ដែលបានធ្វើចំណាកស្រុកពីតាមបណ្តាខេត្តនានា មកសិក្សា និងប្រកបមុខរបរប្រចាំថ្ងៃនៅរាជធានីភ្នំពេញ ហើយត្រូវការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់យកទៅប្រើប្រាស់ តម្រូវឱ្យពួកគាត់ត្រលប់ទៅសុំសេចក្តីចម្លងពីសាលាក្រុង ស្រុក នៃលំនៅឋានដែលគាត់បានចុះបញ្ជីកន្លងមក ដែលធ្វើឱ្យមានការលំបាក និងត្រូវចំណាយទាំងពេលវេលា និងសោហ៊ុយធ្វើដំណើរ។

ដើម្បីបង្កលក្ខណៈងាយស្រួល ការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់យកទៅប្រើប្រាស់ សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជាទីតិជនដែលរស់នៅក្នុងផ្ទះជាមួយ អាចមកស្នើសុំចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាននៅផ្លូវជាតិលេខ១ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ (ទល់មុខបុរី ប៉េង ហួត បឹងស្នោរ) នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សេចក្តីដូចបានជូនដំណឹងនេះ សូមប្រជាពលរដ្ឋនៅទូទាំងប្រទេសមេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧